UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# សេចក្តីថ្លែងការណ៍ជាសាធារណៈ ២៩ កក្កដា ឆ្នាំ ២០០៨

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) ស្វាគមន៍របាយ-ការណ៏ដែលថាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកម្ពុជាអាណត្តិទី៤ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ បានប្រព្រឹត្តទៅក្នុងបរិយាកាសមួយដែលភាគច្រើនមានសភាពស្ងប់ស្ងាត់ និងគ្មានអំពើហឹង្សា ។

ការសង្កេតការណ៏របស់ការិយាល័យ(OHCHR) មិនបានផ្តោតការយកចិត្តទុកដាក់លើការងារបច្ចេកទេសនៃការបោះឆ្នោតទេ ។ ការិយាល័យនេះ បានផ្តោតការយកចិត្តទុកដាក់លើអំពើហឹង្សា និងការបំភិតបំភ័យធ្ងន់ធ្ងន់បំផុតនៅមុនពេល ក្នុងពេល និងក្រោយពេលបោះឆ្នោត និងមានគោលដៅកំណត់អំពីថាតើករណើទាំងនេះពិតជាកើតមានមែនឬអត់ ហើយវាជារឿងនយោបាយឬមិនមែន ។ ថ្ងៃនេះ ការិយាល័យ(OHCHR) ចេញសេចក្តីសង្កេតបឋមរបស់ខ្លួន ។

ដោយបានពិនិត្យលើការអះអាងថាមានការសម្លាប់ និងការស្លាប់ដោយសង្ស័យនៃសកម្មជននយោបាយថ្នាក់មូលដ្ឋាន ដែលការិយាល័យ(OHCHR)បានដឹងចាប់ពីដើមឆ្នាំ២០០៨ មក រហូតមកទល់ថ្ងៃនេះ ការិយាល័យនេះរកមិនឃើញមានភស្តុតាងណាមួយអាចជឿបានថាជារឿងនយោបាយឡើយ ។ នេះជាការរីកចំរើនមួយគួរឱ្យស្វាគមន៏ដែលមានការផ្ទុយគ្នាស្រឡះទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីអណត្តិ ដែលពោរពេញទៅដោយអំពើហឹង្សានយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យ(OHCHR)នៅមានកង្វល់ជាខ្លាំងអំពីករណិឃាតកម្មនៅថ្ងៃទី១១ ខែកក្កដា លើរូបលោក ឃឹម សំបូរ អ្នកកាសែតដែលមាននិន្នាការខាងគណបក្សប្រឆាំង *កាសែតមនសិកាខ្មែរ* និង និងកូនប្រុសរបស់គាត់ឈ្មោះ ខាត់ សារិន្ទភាតា ។ ការិយាល័យ(OHCHR) គូសបញ្ជាក់ជាថ្មីអំពីការអំពាវនាវដល់អាជ្ញាធរឱ្យធ្វើការស៊ើបអង្កេតមួយដែលជឿទុកចិត្តបានទៅលើករណើនេះ ហើយនាំខ្លួនជនល្មើសទៅតុលាការដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ។ ការិយាល័យ(OHCHR) បានកត់សំគាល់ថាមិនទាន់មានការចាប់ខ្លួនជនល្មើសនៅឡើយទេ ក្នុងករណើឃាតកម្មភាគច្រើនដែលការិយាល័យ(OHCHR)បានពិនិត្យក្នុងឆ្នាំ២០០៨ ដោយរួមទាំងករណើទាំងឡាយដែលគេសង្ស័យថាមិនមែនជារឿងនយោបាយផងដែរ ហើយ

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ថាភស្តុតាងមានក្នុងករណីខ្លះ តែត្រូវបានប្រកាសជាផ្លូវការថាជាការស្លាប់ធម្មតា ឬឧប្បត្តិហេតុ។ ការិយាល័យ (OHCHR) បានគូសបញ្ជាក់ច្រើនលើកច្រើនសារអំពីកង្វល់របស់ខ្លួនអំពីផលប៉ះពាល់ធ្ងន់ធ្ងរបំផុតនៃនិទណ្ឌភាពនេះទៅលើបរិយាកាសនយោបាយ និងសង្គមកម្ពុជា ដោយមិនទាំងគិតដល់ចេតនារបស់ជនល្មើសផងនោះ។

ទន្ទឹមនឹងទទួលស្គាល់ថាអំពើហឹង្សាមានការថយចុះជាទូទៅ បើប្រៀបធៀបនឹងការបោះឆ្នោតកាលពីពេលកន្លងមកក្តី ចាប់ពីដើមឆ្នាំនេះ ការិយាល័យ(OHCHR) បានសង្កេតឃើញថានៅពេលយុទ្ធនាការបោះឆ្នោតមានការគាបសង្កត់ ការគំរាមកំហែង ការបំភិតបំភ័យ និងការអូសទាញសកម្មជននយោបាយផ្សេងៗនៅគ្រប់ស្រទាប់ជាន់ថ្នាក់ក្នុងកិច្ចខិតខំប្រឹងប្រែងបញ្ចុះបញ្ចូលអ្នកទាំងនោះប្តូរគណបក្ស។ ឧបាយកលនេះបានដៅលើបុគ្គលមួយចំនួន ជាពិសេស សមាជិកគណបក្សប្រឆាំង ក៏ដូចជានៅតាមតំបន់នានាដែលគណបក្សទាំងនេះមានឥទ្ធិពលខ្លាំង។ នៅក្នុងបរិបទនៃការគាបសង្កត់ឱ្យប្តូរភក្តីភាពគណបក្ស ដែលសកម្មជនគណបក្សសមរង្ស៊ីមួយរូបគឺលោក ទូត សារ៉ន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៨ ខែមីនា នៅខេត្តកំពង់ធំ ដែលជាប់ចោទពីបទបង្ខាំងសមាជិកគណបក្សរបស់ខ្លួនម្នាក់ដោយខុសច្បាប់ ដែលកំពុងដំណើរការនៃការចូលជាសមាជិកគណបក្សប្រជាជន។ ការិយាល័យ (OHCHR) រកមិនឃើញមានភស្តុតាងណាមួយគាំទ្រដល់ការចោទប្រកាន់លើរូបលោក សារ៉ន ដែលបច្ចុប្បន្នកំពុងជាប់ពន្ធនាគាររងចាំសវនាការ។ ជនជាប់ចោទបីនាក់ទៀតនៅក្នុងករណីដដែលនេះ កំពុងប្រឈមមុខនឹងការចាប់ខ្លួន។

ការិយាល័យ(OHCHR) ក៏បានសំគាល់ឃើញមានការអះអាងជាសាធារណៈអំពីសកម្មភាពភេរវកម្មរបស់គណបក្សសមរង្ស៊ី ថ្លែងអះអាងដោយសមាជិកមួយរូបដែលរត់ចោលជួររបស់គណៈបក្សនេះ និងការប្រកាសអំពីការស៊ើបអង្កេតផ្នែកយោធាទៅលើការអះអាងនេះ។ មិនមានភស្តុតាងណាមួយអាចជឿទុកចិត្តបានដែលគាំទ្រដល់ការទាមទារទាំងនេះឡើយ។ ការិយាល័យ(OHCHR)មានការព្រួយបារម្ភថាទង្វើទាំងនេះមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើគណបក្សនយោបាយក្នុងការរៀបចំ ការធ្វើយុទ្ធនាការ និងការគាំងកងជំនួយ ក៏ដូចជាលើការត្រៀមខ្លួនរបស់អ្នកបោះឆ្នោតដើម្បីចូលរួមក្នុងការពិភាក្សាជាសាធារណៈអំពីបញ្ហានយោបាយបច្ចុប្បន្ន។

ការិយាល័យ(OHCHR) មានកង្វល់យ៉ាងខ្លាំងចំពោះការគ្មានសមធមិក្នុងចំណោមគណបក្សនយោបាយក្នុងប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងប្រព័ន្ធអេឡិត្រូនិច ទាំង ប្រព័ន្ធព័ត៌មានតាម កាសែត និងផលប៉ះពាល់ជាយកថាហេតុលើសិទ្ធិរបស់អ្នកបោះឆ្នោតក្នុងការជ្រើសរើស តាមរយៈការទទួលបានព័ត៌មានគ្រប់គ្រាន់ជាមុនៗការបោះឆ្នោត។ ការិយាល័យ(OHCHR) កត់សំគាល់ជាពិសេស ចំពោះការបិទស្ថានីយវិទ្យុអង្គររដ្ឋាក្នុងខេត្តក្រចេះ បន្ទាប់ពីវិទ្យុនេះបានលក់ម៉ោងផ្សាយទៅឱ្យគណបក្សប្រឆាំងនានា ហើយមានការសោកស្តាយដោយសារថាស្ថានីយនេះមិនត្រូវបានគេអនុញ្ញាតឱ្យផ្សាយនៅមុនការបោះឆ្នោត។ ការិយាល័យ(OHCHR) មានកង្វល់ទៀតថា ដោយសារតែការចាប់ខ្លួន និងការឃុំខ្លួនមួយសប្តាហ៍ពេញរបស់លោក ដាំ សិទ្ធិ ដែល*ជាសមាជិកគណបក្សប្រឆាំង និងនិពន្ធនាយកនៃកាសែតមនសិការខ្មែរ* នៅមុនការចាប់ផ្តើមយុទ្ធនាការបោះឆ្នោតក្រោយ

ពេលដែលកាសែតនេះបានរាយការណ៍អំពីសន្ទរកថារបស់លោកសមរង្ស៊ី មេដឹកនាំគណបក្សប្រឆាំង និងការគំរាមចោទប្រកាន់លោករង្ស៊ី អំពីសន្ទរកថានោះ ។ ការចោទប្រកាន់លើលោកដាំ សិទ្ធិ នៅតែព្យួរនៅឡើយ ។

ការិយាល័យ (OHCHR) ជំរុញលើកទឹកចិត្តឱ្យគណបក្សនយោបាយទាំងអស់នឹងរួមចំណែករក្សាឱ្យមានបរិយាកាសស្ថាបនា និងដោះស្រាយបណ្តឹង ឬការខ្វែងគំនិតគ្នាដោយសន្តិវិធី ក្នុងស្មារតីគោរពតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍សិទ្ធិមនុស្ស ។